

# ខ្មែរ បែបណា ?

នាង កុយ ពិសី អនុប្រធាន របស់ លោក វ៉ា គឹម ហុង ថ្លែងថា គាត់ ធ្វើការជាង ២០ឆ្នាំ ហើយ ក្នុង កិច្ចការ ព្រំដែន ខ្មែរ-យៀកណាម - ដោយទឹកដីខ្មែរបុរាណ ជំទូលំទូលាយ ពេកមកដល់បច្ចុប្បន្ននេះ មានប្រជាជនខ្មែរខ្លះ រស់លើដី យៀកណាម ដោយមិនដឹងខ្លួនផង - ហើយសព្វថ្ងៃ ផ្ទៃក្រឡាដីខ្មែរយើងមិនអាចដឹងពិតប្រាកដបាន នៅពេលណាដែលយើងមិនទាន់បោះប្រគូលព្រំដែន ខ្មែរ-យៀកណាមរួចស្រេច - (Sic)

បើ ក្រុម លោក វ៉ា គឹម ហុង គាត់ ក្នុងនាម ជាភាគីខ្មែរ ចរចារ ជាមួយ ភាគីយៀកណាម អត់ដឹងថា ផ្ទៃក្រឡា ប្រទេសខ្លួនមានប៉ុន្មានផង តើពួកគាត់មានអ្វីទៅ ចរចារ គូសខ្សែព្រំដែនជាមួយ យៀកណាម បាន មានតែនៅពេល ចរចារនោះ ពួកគាត់ នាំគ្នាអង្គុយស្ដាប់ ភាគីយួន គេបកស្រាយ អំពីទឹកដីខ្មែរដូចយួនគេ បណ្ដុះគំនិត ក្នុងសតិ លោក ហោ ណាំ ហុង, វ៉ា គឹ-ម ហុង និង នាង កុយ ពិសី ថា ជូនកាល ប្រជាជនខ្មែរ រស់នៅលើ ទឹកដីយួន ដោយ មិនដឹងខ្លួនផង។ សំដីបែបនេះហ៊ុនសែន ស្ដាប់មិនឮទេ ព្រោះ វាមិននៅក្នុងរលកអាកាស សំរាប់ស្ដាប់សំលេង របស់ពួកគាត់ បែទៅជាឮ សំដីលោក ហុង សុខហួរ និយាយពីការពិតទៅវិញ បញ្ជាឲក្រុមដៃទី៣ របស់ខ្លួន ទៅចាប់ គាត់ទាំងទទឹងទិស ចោទគាត់ជាជនក្បត់ជាតិ។ តើសំដី ហោ ណាំហុង និង នាង កុយពិសី មិនជាសំដីក្បត់ជាតិ ទេរឺអី ?

ក្រុម លោក ហ៊ុន សែន គាត់ចង់ យក នាង កុយ ពិសី មកជំនួសលោក វា គឹម ហុង ក្នុងវិស័យ ទំនាក់ទំនង ជាសាធារណ: ព្រោះលោក វ៉ា គឹម ហុង គាត់ពូកែតែស្ដាប់យួនបកស្រាយ តែដូចជាខ្វះ វោហារ សំរាប់ យកសំដីយួន មកពន្យល់ប្រជាពលរដ្ឋខ្មែរ។ វារឹតតែមានមហន្តរាយ ថែមទៅទៀត ព្រោះនាង កុយ ពិសី មិនត្រឹម តែខ្វះវោហារ ថែមទាំងជា ***ភីនារី*** (femme arrogante) ទៅទៀត និយាយគ្មានដឹងទិសដំបន់អ្វីបន្តិចឡើយ មើលងាយប្រជាពលរដ្ឋខ្មែរ។ សួរថាតើ ក្រុម លោក ហ៊ុន សែន សព្វថ្ងៃ ខ្វះ អ្នកនាំពាក្យ ឬ ? ព្រោះឃើញប្រើតែមនុស្ស អចិត្ត ឬ ល្ងង់ខ្លៅ(ignare) ក្នុងសង្គម និង ជនអនិផល ( ingrat) សំរាប់ក្រុមខ្លួន ដូចជា លោកសុខ ទូច ឈាន វុន និង នាង កុយ ពិសី។តែក្រុម លោក ហ៊ុនសែន មិនអាច យល់ដោយវិញ្ញាណ កើត នោះឡើយ ព្រោះអស់ លោកអ្នកនាង ទាំងនេះ វាចេញពី ព្រលឹង របស់ពួកគាត់តែម្ដង។ ត្រូវដឹងថា យួនគេមិនដែលយកខ្មែរអ្នកចេះដឹង មកប្រើនោះឡើយ គេប្រើតែខ្មែរល្ងង់ខ្លៅ ឬ ខ្មែរដែលមាន ឈាមយួនតែប៉ុណ្ណោះ។ តើខ្មែរបែប ឈាង វុន, សុខ ទូច និងនាង កុយ ពិសី ជាខ្មែរបែបណា ?

ដោយ ឧប សៅ សង្ខា
១៨ សីហា ២០១៥